ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងសុខាភិបាល មានកិត្តិយសសូមជំរាបជូនអស់លោក លោកស្រី ជាវេជ្ជបណ្ឌិត និងឱសថការីទាំងអស់ ដែលទទួលខុសត្រូវគ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ, ឱសថស្ថាន-ឱសថស្ថានរង, អាជីវករ និងប្រជាពលរដ្ឋទាំងអស់ ឱ្យបានជ្រាបថា :

យោងលិខិតលេខ Servier 02/09 DKSH/RL ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៩ របស់ក្រុមហ៊ុន ឌី ខេ អេស អេច ខេមបូឌា និងដោយពិនិត្យឃើញនៅលើទីផ្សារកម្ពុជាបច្ចុប្បន្ននូវឱសថចំនួន ៤មុខ របស់រោងចក្រផលិតឱសថ Servier ដែលបានចុះបញ្ជិកានៅក្រសួងសុខាភិបាល នៃប្រទេសកម្ពុជា និងនាំចូលស្របច្បាប់ដោយ ក្រុមហ៊ុន DKSH (CAMBODIA) ។ ឱសថទាំង ៤មុខ នេះ ត្រូវបាននាំចូលដោយខុសច្បាប់ ដែលមានអត្តសញ្ញាណ ការវេចខ្ចប់ របៀបបង្ហាញ និង សំបកប្រអប់ដូចគ្នាបេះបិទនឹងឱសថស្របច្បាប់ តែពុំមានបិទស្លាកបំរ៉ែ និងគ្មានលេខ បញ្ជិកាទេ គ្រាន់តែមានបិទ Notice ជាអក្សរវៀតណាម ដែលមានលេខឡូតិ៍ ថ្ងៃផុតកំណត់ដូចខាងក្រោម :

| | | | |
|---|---|---|---|
| 1-Diamicron MR | 60's | Lot N° 820185 | Exp. 10/2011 |
| 2-Natrilix SR | 30's | Lot N° 827110 | Exp. 09/2010 |
| 3-Vastarel MR | 60's | Lot N° 818340 | Exp. 05/2011 |
| 4-Vastarel 20mg | 60's | Lot N° 825251 | Exp. 08/2011 |

និងមានរូបភាពជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុនេះ អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងឱសថ ក្រសួងសូមមានវិធានការដូចតទៅ :

១. គ្រឹះស្ថាននាំចូលឱសថ ក្នុងស្រុក ដែលធ្វើប្រតិបត្តិការនាំចូល ឬ ចែកចាយឱសថខាងលើ ត្រូវចាត់តាំងការប្រមូលឱសថទាំងនោះ ពីឱសថស្ថាន-ឱសថស្ថានរងនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២. គ្រឹះស្ថានលក់ឱសថទាំងអស់ត្រូវបញ្ឈប់ការតាំងលក់ឱសថខាងលើ ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះតទៅ ។

៣. គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវមានវិធានការ ធ្វើការណែនាំ ដល់គ្រប់សាខាគ្រឹះស្ថាននាំចូលឱសថ-ឱសថស្ថាន-ឱសថស្ថានរង ដូចមានក្នុងចំណុច១ខាងលើ ។

៤. ក្រសួងនឹងមានវិធានការតឹងរឹងតាមផ្លូវច្បាប់ ចំពោះឱសថស្ថាន-ឱសថស្ថានរងទាំងឡាយណា ដែលនៅតែបន្តការតាំងលក់ឱសថខាងលើនេះ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ឱសថការី ជូ-យិនស៊ីម

<u>ចម្លងជូន</u> :

- ក្រសួងព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយ"
- លេខាធិការដ្ឋាន នៃគណៈកម្មាធិការនិងគណៈកម្មការរាជធានី-ខេត្ត ប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- គ្រប់មន្ទីរពេទ្យជាតិ
- គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- គ្រប់ស្ថានីយវិទ្យុ-ទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- គ្រប់សារព័ត៌មាន "ដើម្បីជួយផ្សព្វផ្សាយ"
- គ្រប់គ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ ដែលពាក់ព័ន្ធ "ដើម្បីអនុវត្ត"
- គ្រប់ឱសថស្ថាន-ឱសថស្ថានរង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

553